# សហគមន៍ខ្មែរកម្ពុជាក្រោម

**THE KHMER KAMPUCHEA KROM COMMUNITY**
**LA COMMUNAUTÉ DU KHMER KAMPUCHEA KROM**

# សេចក្តីអំពាវនាវ

ដើម្បីសម្តែងនូវកតញ្ញូតាធម៌ និងគារវកិច្ច ចំពោះព្រះវិញ្ញាណក្ខន្ធព្រះវីរសមណៈ ព្រះវិញ្ញាណក្ខន្ធព្រះវីរព្រះមហាក្សត្រ វិញ្ញាណក្ខន្ធវីរបុរស វីរនារី វីរយុទ្ធជន វីរយុទ្ធនារីខ្មែរស្នេហាជាតិ ដែលបានពលីជីវិតក្នុងបុព្វហេតុជាតិ សាសនា និងមាតុភូមិខ្មែរ ជាពិសេសមាតុភូមិខ្មែរកម្ពុជាក្រោម និងប្រាព្ធទិវាកាន់ទុក្ខជាតិខ្មែរខួបគម្រប់ ៧៣ឆ្នាំ ថ្ងៃអាណានិគមបារាំងផ្ទេរទឹកដីខ្មែរកម្ពុជាក្រោម ឱ្យអាណានិគមវៀតណាមត្រួតត្រាបន្តរហូតសព្វថ្ងៃ អង្គការ-សមាគមខ្មែរកម្ពុជាក្រោម បានរៀបចំធ្វើពិធីបុណ្យរាប់បាត្រព្រះសង្ឃចំនួន ១៩៤៩អង្គ និងប្រារព្ធទិវាកាន់ទុក្ខជាតិខ្មែរ ៤ មិថុនា ជារៀងរាល់ឆ្នាំ។

ឆ្នាំនេះ អង្គការ-សមាគមខ្មែរកម្ពុជាក្រោម បានសម្រេចជាឯកច្ឆន្ទពន្យារពេលប្រារព្ធពិធីបុណ្យរហូតដល់ថ្ងៃអាទិត្យ ទី០៣ ខែកក្កដា ព.ស.២៥៦៦ គ.ស.២០២២ ដោយមូលហេតុ ព្រះរាជាណាចក្រកម្ពុជាបានរៀបចំបោះឆ្នោតឃុំ សង្កាត់ ចំថ្ងៃប្រារព្ធពិធីបុណ្យ។

សេចក្តីដូចបានប្រគេននិងជម្រាបជូនខាងលើ យើងខ្ញុំសូមលំឱនកាយគោរពអំពាវនាវដល់ព្រះថេរា-នុត្ថេរៈគ្រប់ព្រះអង្គ បងប្អូនរួមឈាម និងសប្បុរសជនទាំងអស់ ព្រះមេត្តា និងមេត្តាជួយឧបត្ថម្ភជាទឹកបរិសុទ្ធ ចង្ហាន់ព្រះសង្ឃ និងថវិកាទៅតាមសទ្ធាជ្រះថ្លា ដើម្បីយើងខ្ញុំមានលទ្ធភាពរៀបចំចាត់ចែងពិធីបុណ្យប្រវត្តិសាស្រ្តនេះឱ្យបានជោគជ័យដូចរៀងរាល់ឆ្នាំ។

យើងខ្ញុំមានសេចក្តីសង្ឃឹមយ៉ាងមុតមាំទៅលើស្មារតីស្នេហាជាតិ ស្នេហាព្រះពុទ្ធសាសនា និងការគោរពនូវព្រះវិញ្ញាណក្ខន្ធ និងវិញ្ញាណក្ខន្ធនៃបុព្វបុរខ្មែរស្នេហាជាតិរបស់ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ បងប្អូនរួមជាតិ ពិតជាលះបង់សម្ភារៈឬថវិកាតាមសទ្ធាជ្រះថ្លា ក្នុងការចូលរួមជាកុសលផលបុណ្យដើម្បីឧទ្ទិសកុសលប្រគេន ថ្វាយ និងជូនព្រះវិញ្ញាណក្ខន្ធ និងវិញ្ញាណក្ខន្ធ ព្រះវីរសមណៈ ព្រះវីរព្រះមហាក្សត្រ និងវីរបុរសរបស់យើងជាក់ជាមិនខាន។

កម្មវិធីបុណ្យនឹងប្រព្រឹត្តទៅចាប់ពីម៉ោង ៨ព្រឹករហូតដល់ម៉ោង ១២ថ្ងៃត្រង់ នៅថ្ងៃអាទិត្យ ទី០៣ ខែកក្កដា ព.ស.២៥៦៦ គ.ស.២០២២ ក្រោមព្រះអធិបតីភាពព្រះរាជតំណាងដ៏ខ្ពង់ខ្ពស់នៃព្រះករុណាជាអង្គម្ចាស់ជីវិតលើត្បូង ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា។ ទីកន្លែងប្រារព្ធពិធី៖ ទីស្នាក់ការសហគមន៍ខ្មែរកម្ពុជាក្រោម ស្ថិតនៅភូមិគោកឃ្លាង សង្កាត់គោកឃ្លាង ខណ្ឌសែនសុខ រាជធានីភ្នំពេញ (ទល់មុខផ្សារឈូកមាស)។ មានរាប់បាត្រព្រះសង្ឃជានិមិត្តរូប ១៩៤៩អង្គ ព្រមទាំងនិមន្តព្រះសង្ឃជារបង្សុកូលឧទ្ទិសកុសលជាកិច្ចបង្ហើយបុណ្យ។

សេចក្ដីអំពាវនាវនេះ ទុកជាសេចក្ដីអញ្ជើញបងប្អូនរួមជាតិទាំងអស់ចូលរួមរាប់បាត្រព្រះសង្ឃ និង គោរពព្រះវិញ្ញាណក្ខន្ធព្រះវីរសមណៈ ព្រះវិញ្ញាណក្ខន្ធព្រះវីរព្រះមហាក្សត្រ និងវិញ្ញាណក្ខន្ធវីរបុរស វីរយុទ្ធជន វីរយុទ្ធនារីខ្មែរស្នេហាជាតិ ដោយសេចក្ដីគោរពដ៏ខ្ពង់ខ្ពស់បំផុត៕

***ទីកន្លែងទទួលជំនួយ៖***

- នៅគ្រប់ទីស្នាក់ការអង្គការ-សមាគមខ្មែរកម្ពុជាក្រោម និងសហាគមន៍ខ្មែរកម្ពុជាក្រោម ប្រចាំទ្វីបអាមេរិកខាងជើង។
- តាមគណនីធនាគារ ABA: 001 751 525 Vibol, Chantrear, និង Mora

ថ្ងៃអាទិត្យ ១៣កើត ខែជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ, ត្រូវនឹងថ្ងៃទី១២ ខែមិថុនា គ.ស.២០២២

**ទូរស័ព្ទលេខ៖**
០៩៦ ៨៣ ២៣ ៧២៥
០១២ ៥១៩ ៥២០

**ប្រធានគណៈកម្មការបុណ្យ**

**ថាច់ សេដ្ឋា**
នាយកប្រតិបត្តិសហាគមន៍ខ្មែរកម្ពុជាក្រោម
អតីតសមាជិកព្រឹទ្ធសភា

**នៅទ្វីបអាមេរិកខាងជើង៖**

- លោក គិម សកល ៩៧៨.៥៩៦.៥១២៦
- លោក គិម វុឌ្ឍី ៨៦៤.៥៩៥.១៩៩១
- លោក គិម សារេត ៩៧៨.៣២៨.៥៤៣៥
- លោក សឺន ស៊ីណា ២៦៧.២៥២.៣៦០៨
- លោក វិញ ថន ៩០៩.៥៧១.៣៥៩២
- លោក ថាច់ សារី ២០៦.៣០៤.១៥៣៥

សម្រាប់ព្រះករុណា ព្រះថេរានុត្ថេរៈ បងប្អូនជនរួមជាតិ និងសប្បុរសជន គង់និងរស់នៅសហរដ្ឋអាមេរិក ប្រទេសកាណាដា ទ្វីបអឺរ៉ុប ប្រទេសអូស្ត្រាលី ប្រទេសនូវហ្សេឡង់ ព្រមទាំងបណ្ដាប្រទេសនានា សូមមេត្តាផ្ញើសែករូបិយវត្ថុទៅលោក ថាច់ រ៉ា តាមរយៈអាសយដ្ឋាននៅខាងក្រោមនេះ៖

For residents of U.S., Canada, Europe, Australia, New Zealand and other countries, please kindly make payable personal check, traveler's check or money order and send it to:

**RA THACH**
P.O. BOX 37502, PHILADELPHIA, PA 19148, U.S.A.

សូមថ្លែងអំណរព្រះគុណ និងអំណរគុណយ៉ាងជ្រាលជ្រៅទុកជាមុន។

Thank you very much in advance for your support.